# ពិធីចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនជាងសាងសង់ឡជីវឧស្ម័ន នៅខេត្តកែប

កាលពីព្រឹកថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៩ នៅសាលប្រជុំសាលាខេត្តកែប សេដាកបានរៀបចំពិធីចុះកិច្ចព្រមព្រៀងមួយ រវាងក្រុមហ៊ុនជាងសាងសង់ឡជីវឧស្ម័ន និងកម្មវិធីឡជីវឧស្ម័នថ្នាក់ខេត្ត និងថ្នាក់ជាតិក្រោមការឧបត្ថម្ភថវិកាដោយកម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ។ កម្មវិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ឯកឧត្តម **នូ មុត** ទីប្រឹក្សារបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងឯកឧត្តម **កៅ ផល** ប្រធាននាយកកដ្ឋានផលិតកម្ម និងបសុព្យាបាល។

កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិបានចាប់ដៃគូ សហការជាមួយអង្គការ សេដាក ចាប់តាំងពីដើមឆ្នាំ២០០៧ ដែលកាលពីដំបូង សេដាក ធ្វើការក្នុងរូបភាពជាអ្នកផ្សព្វផ្សាយ ដើម្បីរកអតិថិជននៅក្នុងខេត្តចំនួន ៥ គឺខេត្តកណ្តាល កំពង់ចាម ស្វាយរៀង តាកែវ និងកំពង់ស្ពឺ ហើយដែលកាលនោះ សេដាក អាចចូលរួមចំណែករកអតិថិជនសាងសង់ឡជីវឧស្ម័នអោយកម្មវិធីបានចំនួន ៣២០ ឡ។

ដោយឃើញពីសក្តានុពលរបស់ សេដាក ក្នុងការផ្សព្វផ្សាយ នៅចុងឆ្នាំ២០០៧ កម្មវិធីថ្នាក់ជាតិ បានធ្វើការសាកល្បងប្រគល់ខេត្តចំនួនមួយគឺខេត្តកំពតអោយ សេដាក ទទួល ខុសត្រូវក្នុងការអនុវត្តការងារ ។ ជាលទ្ធផលយើងអាចធ្វើការសាងសង់ឡបានចំនួន ៣៩៧ឡ លើសផែនការប្រចាំឆ្នាំដែលកំណត់ត្រឹមតែ២០០ ឡ ។ លុះមកដល់ចុងឆ្នាំ២០០៨ កម្មវិធីថ្នាក់ជាតិបានធ្វើការប្រគល់ខេត្តចំនួន ២ បន្ថែមទៀតគឺខេត្តព្រៃវែង និងខេត្តកណ្តាល ដើម្បីអោយ សេដាក ទទួលខុសត្រូវបន្ថែម។ បើតាមលទ្ធផលជាក់ស្តែង មកដល់ខែឧសភាឆ្នាំ ២០០៩ នេះ សេដាក បានធ្វើការផ្សព្វផ្សាយ និងសាងសង់ឡបានចំនួន ១១២០ ឡ។

ដើម្បីឈានទៅសាងសង់ឡបានគ្រប់ផែនការ និងសាងសង់ប្រកបដោយគុណភាព និងមាននិរន្តរភាពទៅថ្ងៃខាងមុខ កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិបានរៀបចំអោយមានកម្មវិធីអភិវឌ្ឍន៍វិស័យឯកជន (PSD) ដោយរៀបចំជាងដែលមានសក្តានុពល អោយបង្កើតជាក្រុមហ៊ុនសាងសង់ឡ ក្រោមការបណ្តុះបណ្តាលពីមជ្ឈមណ្ឌលអភិវឌ្ឍន៍វិស័យឯកជន ( CIEDC )។